# សេចក្តីប្រកាសព័ត៌មានសម្រាប់កម្មករជួលកម្លាំងពលកម្ម

ច្បាប់ជួលកម្លាំងពលកម្មនៅរដ្ឋអូស្ត្រាលីខាងត្បូង តម្រូវឲ្យអ្នកផ្គត់ផ្គង់ជួលកម្លាំងពលកម្មបំពេញសេចក្តីប្រកាសព័ត៌មាននេះ ហើយប្រគល់វាទៅឱ្យកម្មករជួលកម្លាំងពលកម្ម រៀងរាល់ពេលដែលពួកគេត្រូវបានប្រគល់ដល់អាជីវកម្មដើម្បីអនុវត្តការងារ។

ក្នុងភាពជាកម្មករជួលកម្លាំងពលកម្ម វាជាការសំខាន់ដែលត្រូវដឹងអំពីសិទ្ធិ និងសិទ្ធិទទួលបានរបស់អ្នក។

ឈ្មោះអ្នកផ្គត់ផ្គង់ជួលកម្លាំងពលកម្ម

លេខអាជ្ញាប័ណ្ណរបស់អ្នកផ្គត់ផ្គង់

ឈ្មោះកម្មករជួលកម្លាំងពលកម្ម

កាលបរិច្ឆេទកម្មករចាប់ផ្តើមជាមួយអ្នកផ្តល់ការងារ

ឈ្មោះអាជីវកម្មដែលកម្មករត្រូវបានផ្គត់ផ្គង់ទៅឱ្យ (អ្នកផ្តល់ការងារ)

អត្រាប្រាក់ឈ្នួល *(ឧទាហរណ៍ ក្នុងមួយម៉ោង/ក្នុងមួយផុង/ក្នុងមួយជួរ)*

វិធីទូទាត់ប្រាក់៖

- ☐ ការផ្ទេរប្រាក់តាមធនាគារ
- ☐ សាច់ប្រាក់
- ☐ មូលប្បទានប័ត្រ
- ☐ ផ្សេងទៀត - សូមបញ្ជាក់

ទីស្នាក់អាស្រ័យដែលបានផ្តល់

- ☐ បាទ/ចាស
- ☐ ទេ

ហត្ថលេខារបស់អ្នកផ្គត់ផ្គង់ជួលកម្លាំងពលកម្ម

ហត្ថលេខារបស់កម្មករជួលកម្លាំងពលកម្ម

អ្នកផ្គត់ផ្គង់ជួលកម្លាំងពលកម្មត្រូវរក្សាទុកច្បាប់ចម្លងនៃសេចក្តីជូនដំណឹងនេះមួយច្បាប់សម្រាប់រយៈពេល១២ខែ ហើយត្រូវបង្ហាញសេចក្តីប្រកាសព័ត៌មាននេះជូនដល់មន្ត្រីមានសមត្ថកិច្ច តាមការស្នើសុំ។

**សូមមើលព័ត៌មាននៅលើទំព័រម្ខាងទៀត សម្រាប់កិច្ចការទាំងឡាយដែលអ្នកគួរដឹងក្នុងភាពជាកម្មករជួលកម្លាំងពលកម្ម។**

# អ្វីដែលអ្នកគួរដឹងក្នុងភាពជាកម្មករជួលកម្លាំងពលកម្ម

## សុខភាព និងសុវត្ថិភាព

អ្នកគួររំពឹងថានិយោជកៈ

- ផ្តល់បរិដ្ឋានការងារប្រកបដោយសុវត្ថិភាព និងឧបករណ៍ការពារផ្ទាល់ខ្លួនចាំបាច់
- ផ្តល់ការបណ្តុះបណ្តាលគ្រប់គ្រាន់ អំពីរបៀបធ្វើប្រតិបត្តិការឧបករណ៍ជាក់លាក់
- គូសបញ្ជាក់ពីកាតព្វកិច្ចសុខភាព និងសុវត្ថិភាពការងារ គោលការណ៍និងនីតិវិធីនៅកន្លែងធ្វើការ រួមទាំងនីតិវិធីសម្រាប់គ្រាអាសន្នទាំងអស់។

វាគឺជាទំនួលខុសត្រូវរបស់អ្នកក្នុងការៈ

- សួរ ប្រសិនបើអ្នកមិនប្រាកដពីរបៀបអនុវត្តការងារដោយសុវត្ថិភាព
- អនុវត្តតាមការណែនាំ និងធ្វើការដោយសុវត្ថិភាព
- បញ្ឈប់ការងារដែលគ្មានសុវត្ថិភាពណាមួយជាបន្ទាន់ ហើយជូនដំណឹងទៅអ្នកត្រួតពិនិត្យរបស់អ្នក
- រាយការណ៍ភ្លាមពីការរងរបួសណាមួយ ឬគ្រោះថ្នាក់ដែលហៀបនឹងកើតមាន។

ប្រសិនបើអ្នកមានក្តីបារម្ភអំពីសុវត្ថិភាពនៅកន្លែងធ្វើការរបស់អ្នក សូមទូរស័ព្ទទៅ Safework SA លេខ **1300 365 255** ឬចូលមើលវិបសៃថ៍ www.safework.sa.gov.au។

អ្នកអាចដាក់ពាក្យបណ្តឹងតវ៉ានៅពេលណាមួយ ហើយអ្នកមិនចាំបាច់ផ្តល់ឈ្មោះរបស់អ្នកទេ។

## ធ្វើការនៅក្នុងប្រទេសអូស្ត្រាលី

ប្រសិនបើអ្នកមិនមែនជាពលរដ្ឋរស់នៅក្នុងអូស្ត្រាលីទេ អ្នកនឹងចាំបាច់ត្រូវការទិដ្ឋាការដើម្បីធ្វើការនៅក្នុងប្រទេសអូស្ត្រាលី។ ទិដ្ឋាការត្រូវបានចេញដោយក្រសួងកិច្ចការក្នុងប្រទេស (Department of Home Affairs)។

ពិនិត្យមើលថាតើទិដ្ឋាការរបស់អ្នកអនុញ្ញាតឱ្យអ្នកធ្វើការបានឬអត់ ដោយប្រើសេវាកម្មផ្ទៀងផ្ទាត់សិទ្ធិទទួលបានទិដ្ឋាការតាមអនឡាញ (VEVO) ដោយឥតគិតថ្លៃ នៅត្រង់ https://immi.homeaffairs.gov.au។

អ្នកគួរតែមានលេខសំណុំពន្ធដារ (TFN) បើមិនដូច្នេះទេនោះ អ្នកនឹងត្រូវបង់ពន្ធបន្ថែមទៀត។ ការទទួលបាន TFN គឺឥតគិតថ្លៃទេ។ អ្នកអាចដាក់ពាក្យសុំ TFN តាមអនឡាញ នៅពេលដែលអ្នកមានទិដ្ឋាការការងារ ហើយបានមកដល់ប្រទេសអូស្ត្រាលី។ អ្នកត្រូវដាក់ពាក្យសុំ TFN របស់អ្នកមុនពេលអ្នកចាប់ផ្តើមធ្វើការ ឬឱ្យបានភ្លាមបន្ទាប់ពីអ្នកចាប់ផ្តើមធ្វើការ។

និយោជករបស់អ្នកនឹងស្នើសុំឱ្យអ្នកបំពេញ 'សេចក្តីប្រកាសពីលេខសំណុំពន្ធដារ' ហើយនឹងប្រើព័ត៌មានដែលអ្នកផ្តល់លើសេចក្តីប្រកាសនេះដើម្បីៈ

- គណនាពីចំនួនពន្ធដែលត្រូវដកចេញពីប្រាក់ឈ្នួលរបស់អ្នក
- ផ្តល់ TFN របស់អ្នកទៅឱ្យមូលនិធិសោធននិវត្តន៍របស់អ្នក ដើម្បីឱ្យអាចបង់ប្រាក់ភិតទានសោធននិវត្តន៍ទៅក្នុងមូលនិធិនេះ និងដើម្បីបង់ចំនួនពន្ធត្រឹមត្រូវ។

## ប្រាក់ឈ្នួលរបស់អ្នក

អាជ្ញាធរស៊ើបអង្កេតនិងទទួលបណ្តឹងសាធារណៈផ្នែកការងារយុត្តិធម៌ (Fair Work Ombudsman - FWO) អាចផ្តល់ព័ត៌មាន និងដំបូន្មានជូនអ្នកអំពីសិទ្ធិ និងកាតព្វកិច្ចនៅកន្លែងការងាររបស់អ្នក រួមទាំងបៀវត្សរ៍អប្បបរមា។ ពួកគេក៏អាចជួយអ្នកក្នុងការដោះស្រាយបញ្ហានៅកន្លែងធ្វើការផងដែរ។

ចូលមើលវិបសៃថ៍ www.fairwork.gov.au សម្រាប់ព័ត៌មាន ឧបករណ៍ គំរូ និងសេចក្តីណែនាំ ឬទូរស័ព្ទទៅ FWO លេខ **13 13 94**។

និយោជករបស់អ្នកត្រូវតែផ្តល់ឱ្យអ្នកនូវច្បាប់ចម្លងនៃ របាយការណ៍ព័ត៌មាន អំពីការងារយុត្តិធម៌ (FWIS) នៅពេលអ្នកចាប់ផ្តើមការងារថ្មី។ឯកសារនេះផ្តល់ព័ត៌មានអំពីលក្ខខណ្ឌការងាររបស់អ្នក។ ចូលមើលវិបសៃថ៍ www.fairwork.gov.au/FWIS

## ការទូទាត់ជាសាច់ប្រាក់

និយោជករបស់អ្នកអាចបង់ប្រាក់ឱ្យអ្នកជាសាច់ប្រាក់ ដរាបណាពួកគេៈ

- ដកពន្ធចេញពីប្រាក់ឈ្នួលរបស់អ្នក
- ផ្តល់ឱ្យអ្នកនូវបង្កាន់ដៃប្រាក់ឈ្នួល ដែលបង្ហាញពីចំនួនពន្ធដែលបានដក
- បង់ប្រាក់ចូលក្នុងមូលនិធិសោធននិវត្តន៍របស់អ្នក (ប្រសិនបើអ្នកមានសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍)។

## ប្រាក់សោធននិវត្តន៍ (super)

តាមច្បាប់ និយោជករបស់អ្នកត្រូវតែបង់ប្រាក់ចូលក្នុងមូលនិធិសោធននិវត្តន៍របស់អ្នក ប្រសិនបើអ្នកមានអាយុ១៨ឆ្នាំឡើងទៅ ឬតិចជាង១៨ឆ្នាំ ហើយធ្វើការយ៉ាងតិច៣០ម៉ោង។

មិនថាអ្នកជាអ្នកធ្វើការពេញពេល មិនពេញពេល ការងារម្តងម្កាល ឬអ្នករស់នៅក្នុងប្រទេសអូស្ត្រាលីបណ្តោះអាសន្ននោះទេ។

ប្រាក់សោធននិវត្តន៍ គឺជាប្រាក់ផ្តល់បន្ថែមលើប្រាក់ឈ្នួលរបស់អ្នក។

ជួនកាលអាជីវកម្មបញ្ឈប់ដំណើរការដោយខុសច្បាប់ដើម្បីចៀសវាងការបង់សងបំណុល ដូចជាប្រាក់សោធននិវត្តន៍និងសិទ្ធិទទួលនៃនិយោជិតរបស់អ្នក។ នេះត្រូវបានហៅថា phoenixing (បិទហើយបើកថ្មីមួយផ្សេងទៀតដើម្បីគេចពីការសងបំណុល)។ អ្នកអាចរៀនសូត្រដឹងថែមទៀតនិងរាយការណ៍អំពី phoenixing ទៅកាន់ការិយាល័យពន្ធដារអូស្ត្រាលី (ATO) នៅតាម www.ato.gov.au/phoenix។

ប្រសិនបើនិយោជករបស់អ្នកមិនដកពន្ធ ឬមិនបង់ប្រាក់ចូលក្នុងមូលនិធិសោធននិវត្តន៍របស់អ្នកទេ សូមរាយការណ៍ទៅការិយាល័យពន្ធដារអូស្ត្រាលីតាមទូរស័ព្ទលេខ **1800 060 062**។ អ្នកមិនចាំបាច់ប្រាប់ឈ្មោះអ្នកទេ។

## ដំបូន្មានផ្នែកច្បាប់

សម្រាប់ដំបូន្មានផ្នែកច្បាប់ ទូរស័ព្ទទៅគណៈកម្មការសេវាកម្មច្បាប់ លេខ **1300 366 424** ឬចូលមើលវិបសៃថ៍ www.lsc.sa.gov.au។

ដំបូន្មានផ្នែកច្បាប់គឺឥតគិតថ្លៃហើយពួកគេអាចរៀបចំអ្នកបកប្រែភាសា/អ្នកបកប្រែសម្រាប់អ្នក។

## អ្នកបកប្រែភាសានិយាយ/អ្នកបកប្រែភាសាសរសេរ

ទាក់ទងមកសេវាកម្មបកប្រែភាសាសរសេរ និងនិយាយ (TIS) តាមទូរស័ព្ទលេខ **131 450** ហើយជ្រើសរើសភាសាដែលអ្នកត្រូវការ។

សេវាកម្ម TIS ភាគច្រើនផ្តល់ជូនដោយឥតគិតថ្លៃពីអ្នកមិននិយាយភាសាអង់គ្លេស។ TIS អាចទាក់ទងមកក្រសួងដែលពាក់ព័ន្ធក្នុងនាមអ្នក។ ចូលមើលវិបសៃថ៍ www.tisnational.gov.au។